Free
សារព័ត៌មាន ខ្មែរផុស ស.រ.អា
KhmerPost USA
FREE BIWEEKLY CAMBODIAN ENGLISH NEWSPAPER SINCE 2007
978-677-7163 • VISIT KHMERPOST.US

MAYURA
Video . Fashion Jewelry . Hair Clips
978 998 0707 | 978 4558766
ផ្ញើរអីវ៉ាន់ទៅវិញទៅមកស្រុកខ្មែរ
ផ្ញើរតាមយន្តហោះ 1ផោន $11
ផ្ញើរតាមកប៉ាល់ 1ផោន $4
ធានាសងលុយវិញ បើសិនបាត់

21 branch St. Lowell, MA 01851
Visit us on Facebook : MayuraLowell

## ព័ត៌មានសំខាន់ៗខាងក្នុង...

**សម រង្ស៊ី បន្ថែមល្បឿនដំណើរទៅរកការបែក...** *សូមអាននៅទំព័រទី ០៣*

សូមអាននៅទំព័រទី ០៣



**Thanksgiveing ជាថ្ងៃអរគុណដល់ម្ចាស់ទឹកដីនៃ...** *សូមអាននៅទំព័រទី ០៦*



**អង្គការហ្គីល អ៊ីន ប្រារព្ធកម្មវិធី១០០ឆ្នាំ** *សូមអាននៅទំព័រទី ០៨*




**ភ្លើងឆេះព្រៃនៅកាលីហ្វ័រញ៉ាបានសម្លាប់មនុស្ស...** *សូមអាននៅទំព័រទី ១៣*



# កម្ពុជាដាក់ខ្លួនឱ្យនៅកណ្តាលភ្នក់ភ្លើងសង្គ្រាមត្រជាក់


នាយករដ្ឋមន្ត្រី ហ៊ុន សែន និងប្រធានាធិបតី ស៊ី នៃប្រទេសចិន

ដោយ ពិន សំខុន

ថ្មីៗនេះកម្ពុជាទើបនឹងអនុញ្ញាត្តិឱ្យ"ប្រទេសចិន"សង់បញ្ចប់សំណង់"កំពុងផែទឹកជ្រៅសមុទ្រ"មួយនៅកោះកុង នៅខាងផ្នែកឈូងសមុទ្រថៃ - កំពុងផែនោះ អាចជាចំណតនាវាពាណិជ្ជកម្ម ក៏ដូចនាវាចម្បាំងធំៗរបស់ចិនផងដែរ។ កំពុងផែនេះស្ថិតនៅលើដីផ្ទៃក្រឡា៤៥,០០០ហិកតា ដែលជាដីសម្បទាន៩៩ឆ្នាំ១១០,០០០ហិកតា ឱ្យទៅក្រុមហ៊ុនចិន- ទៀនយីន Development Group) នឹងផ្ទៃក្រឡាដែលនៅសល់(៣៥,០០០ហិកតា)ជាវិនិយោគរបស់ក្រុមហ៊ុនខ្មែរក្នុងនាមនៃទេសចរកម្ពុជា -ក្រុមហ៊ុននោះបានវិនិយោគ $3,8 Billions ក្នុងនាមនៃរចនាសម្ព័ន្ធទេសចរខ្មែរ។ នេះជាដំណឹងដែលគេអាននៅសារព័តិមាន"Asia Times-អេសៀយាថាម"ផ្សាយនៅអាស៊ីនាសប្តាហ៍នេះ បន្ទាប់ពីលោកប្រធានាធិបតីអាមេរិកាំង"Mike Pence ម៉ាយ ផិន" ធ្វើការទីទានយ៉ាងចំហរចំពោះប្រទេសចិនកាលពីកិច្ចប្រជុំ"APEC អាស៊ាន" នៅសឹង្ហបូរីនាពេលថ្មីៗនេះថា "បានប្រើប្រាស់កំពុងផែកម្ពុជាជាកំពុងផែយោធាចិន ហើយគម្រាមកំហែងដល់សន្តិសុខនៅឈូងសមុទ្រចិនខាងត្បូងទៀតផង"។

ដំណឹងនេះ បានធ្វើឱ្យមានការព្រួយបារម្ភដល់ប្រទេសថៃកាន់តែខ្ពស់ នៅពេលដែលកម្ពុជាហក់ចូលយ៉ាងចំហរ ទៅក្នុង"ឥទ្ធិពលយោធា"របស់ចិនចាប់ពីដើមឆ្នាំ២០១៧ ផ្តើមពង្រីកកម្លាំងនៅទំបន់សមុទ្រនាជ្រោយ"ម៉ាឡាកា" ដែលធម្មតានៅក្រោមឥទ្ធិពលរបស់សហរដ្ឋអាមេរិកនោះ ក៏នឹងក្លាយទៅជា"សត្រូវរបស់សហរដ្ឋអាមេរិក"មួយរំពេចភ្លាមដែរ។ តទៅទំព័រទី ០២

# អង្គការ"Barr-Klarman"វិនិយោគ២៥លានដុល្លា លើវិស័យសិល្បៈនៅរដ្ឋម៉ាសាឈូសិត

អត្ថបទដោយ សុបិន្ត ពិន បកប្រែដោយ ពិន សំខុន




អង្គការ"ណែនាំវិស័យសិល្បៈរដ្ឋម៉ាសាឈូសិត Barr-Klarman"បានប្រកាសវិនិយោគមូនិធិ២៥លានដុល្លា ទៅលើសិល្បៈចំនួន២៩នឹងនៅអង្គការវប្បធមិនៅជុំវិញរដ្ឋម៉ាសាឈូសិត ដើម្បីពង្រឹងកម្មវិធីសិល្បៈ ដែលមានសិល្បៈករនឹងទស្សនិកជនចូលរួម។

នៅក្នុងចំណោមអ្នកដែលទទួលការឧបត្ថម្ភក្រុមរោងល្ខោន"ម៉េរីម៉ាកនៅឡូវែល"បានទទួលការឧបត្ថម្ភចំនួន៤៥ម៉ឺនដុល្លា ដែលធ្វើឱ្យគេក្លាយទៅជាមូលនិធីជំនួយដ៏ធំជាងគេបង្អស់ក្នុងប្រវត្តិនៃ

តទៅទំព័រទី ០៤

មេធាវី លុយហាស្កែល
Law Office of Louis S. Haskell
Serving the Cambodian Community since 1987
PERSONAL INJURY របួសរាងកាយ
AUTO ACCIDENTS គ្រោះថ្នាក់ចរាចរ

978-459-8359

16 Pine Street - Lowell, MA | www.attorneyhaskell.com

តមកពីទំព័រទី ០១

## កម្ពុជាដាក់ខ្លួនអោយនៅចំកណ្តាល...

នោះហើយដែលជាអត្ថន័យរបស់ អនុប្រធានាធិបតីអាមេរិកាំង បានសម្តែងការកត់សំគាល់ នាឱកាសប្រជុំ"Asean APEC" ហើយ ដែលបានធ្វើឱ្យសមាជិកអាស៊ាន មានការថ្លឹងថ្លែងពីការជ្រៀតជ្រែកកាន់តែខ្លាំងមកលើកម្ពុជា ដែលនឹងធ្វើឱ្យប្រទេស១នេះក្លាយទៅជានៅក្រោម"អាណានិគមចិន"ដោយមិនដឹងខ្លួន។ ត្រង់នេះ





សំណង់កំពង់ផែចិននៅកោះកុង



អនុប្រធានាធិបតីអាមេរិកាំង ម៉ាយផិន



រដ្ឋមន្ត្រីខាងយោធាវៀតណាម និងអាមេរិកាំង

ហើយដែលអ្នកវិភាគថា"គឺជាការខុសគ្នាវាំងទំនាក់ទំនងជាមួយប្រទេសចិនរបស់សម្តេចព្រះប្រមុខរដ្ឋនរោត្តម សីហនុ នឹងលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលអ្នកទី១បានត្រូវចិនប្រើជាមគ្គុទេសនៃ"ប្រទេសមិនចូលបក្សសម្ព័ន្ធ" រីឯអ្នកទី២ជារណបយោធាក្រោម"អាណានិគមចិន"។

ដើម្បីមកដល់គោលដៅនេះ ចិនបានផ្តល់ឱ្យកម្ពុជានូវជំនួយច្រើនជាងគេ នឹងប្រាក់ខ្ចីក៏មិនចាញ់គេដល់រដ្ឋាភិបាលកម្ពុជា នៅពេលដែលមន្ត្រីធំៗកំពុងត្រូវសហរដ្ឋអាមេរិកនឹងសហភាពអឺរ៉ុបមានបំណងដាក់ទណ្ឌកម្មលើបុគ្គលដែលបានបំផ្លាញ លទ្ធិប្រជាធិបតេយ្យនឹងសេដ្ឋកិច្ចរបស់កម្ពុជា។ ការរំលោភយកដីដ៏ធំទូលាយ ដែលមានប្រជាពលរដ្ឋរស់នៅការរំលោភច្បាប់ចែកដីសម្បទាន(ចែកបានតែ១០,០០០ហិកតាតែប៉ុណ្ណោះ)គឺជាការរំលោភសិទ្ធមនុស្សនឹងរំលោភសន្ធិសញ្ញាក្រុងប៉ារីសឆ្នាំ១៩៩១ វាគ្រប់គ្រាន់សម្រាប់ដាក់ទណ្ឌកម្មណាស់ទៅហើយ - នេះមិនទាន់បូកសរុបពីការរំលាយគណបក្សប្រឆាំងនឹងរលាយសិទ្ធនយោបាយពីសមាជិកសភាក្រុមប្រឹក្សាឃុំសង្កាត់ទៀតផងទេ-ច្បាប់ដែលដាក់កំហិតទណ្ឌកម្ម(ហាមឃាត់មិនឱ្យចូលសហរដ្ឋ-នឹងបង្កកចលនាទ្រព្យសម្បត្តិមានប្រាក់ដុល្លាជាដើម)លើក្រុមគ្រួសារលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ព្រមទាំងគ្រួសារលោក រួមទាំងមន្ត្រីជាច្រើននៃគណបក្សប្រជាជនបានទៅដល់ព្រឹទ្ធសភាហើយរង់ចាំតែសេចក្តីសម្រេចជាចុងក្រោយតែប៉ុណ្ណោះ។

នៅពេលដែលនៅវៀតណាមឯណោះ សហរដ្ឋអាមេរិកបានបង្កើតមូលដ្ឋានជើងទឹកនៅ"កាំរ៉ាញ់" ហើយបើចិនមានមូលដ្ឋានទ័ពជើងទឹករបស់ខ្លួននៅកោះកុង ស្ថានភាពតឹងតែងក្នុងតំបន់ក៏ស្រាប់តែកើនភាពគ្រោះថ្នាក់ភ្លាម ដោយសារតែវៀតណាមក៏កំពុងដឹកនាំការប្រឆាំងនឹងចិនជាមួយម៉ាឡេស៊ីនឹងភីលីពីន ពីបញ្ហាបូរណភាពដែនសមុទ្រនោះ ហើយគ្រោះថ្នាក់នោះឋិតនៅក្នុងកម្ពុជាតែម្តង... តែទស្សនៈនៃអ្នកវិភាគខ្លះនិយាយថា"ប្រទេសថៃមានបំណងនឹងជីកប្រឡាយសម្រាប់នាវាចិនឬនាវាប្រទេសផ្សេង ដឹកទំនិញឆ្លងកាត់ ហើយបើធ្វើបានមែននោះ កំពុងផែចិននៅកោះកុងនឹឋិតនៅចំពីមុខព្រែកជីកនោះ មានន័យថាកំពុងផែកោះកុងជាប្រយោជន៏សេដ្ឋកិច្ចទៅវិញ"។

(នៅមានត)

# ល្បិចងាយស្រួលក្នុងជីវិត

## ផ្ទះបើកម៉ាស៊ីនកំដៅហើយនៅតែត្រជាក់

ខែរងាមកដល់បងប្អូនខ្មែរយើងត្រជាក់ខ្លាំង នាំគ្នាពាក់អាវរងាហើយ ក៏នៅតែត្រជាក់ ហើយ ទៅអង្គុយលើម៉ាស៊ីនកំដៅខំទប់ទល់នឹងអាកាសត្រជាក់។ តែតាមពិតទៅនៅផ្ទះចាស់បន្ទប់មាន



ជញ្ជាំងចាស់ កំដៅវាឡើងទៅលើ ក៏ចេញតាមដំបូលអស់ ដូច្នេះគេត្រូវដាក់ដង្ហាល់មួយ សម្រាប់បក់ខ្យល់ក្នុងបន្ទប់ឱ្យវិលនាំកំឌៅមកក្រោមវិល ទើបកំដៅវារាយស្មើ ធ្វើឱ្យយើងទទួលកំដៅបានប្រសើរ។ ធ្វើរបៀបនេះ នឹងមានកំដៅឡើងស្មើក្នុងបន្ទប់ ហើយយើងក៏មិនចាំបាច់ដំឡើងកំដៅឱ្យខ្ពស់ខ្លាំង ដូច្នេះវានឹងបន្ថយ"ចំណាយនៅលើកំដៅ"បានច្រើនទៀតផង។

ពេលយប់មនុស្សក្នុងផ្ទះ សូម្បីតែកូនក្មេងក៏មិនត្រូវការកំដៅឡើងខ្ពស់ដែរ ដោយសារគេនាំគ្នាចូលដំណេក ហើយដណ្តប់ភួយគ្រប់គ្នា ដូច្នេះសូមកុំភ្លេចបន្ថយកំដៅក្នុងបន្ទប់ពី៣-៥អង្សា (បន្ថយតែសូមកុំបិទតែម្តងឱ្យសោះ) ក្រោមកំដៅធម្មតាក្នុងបន្ទប់ដែលគេមានទម្លាប់ដាក់ពី៦៨ទៅ៧០អង្សានោះ ហើយដម្លើងមកវិញនៅពេលព្រឹកចាប់ពីម៉ោង៥ទៀបភ្លឺ ទៅរហូតដល់ម៉ោង៩ ឬ១០ព្រឹក នៅពេលមនុស្ស ម្នាចេញទៅធ្វើការ ឬក៏ទៅរៀនអស់ រហូតដល់ពេលមានមនុស្សមកពីសាលារៀន ឬមកពីធ្វើការវិញ ទើបតម្លើងកំដៅមកវិញ ម្តងទៀត។ វិធីតម្លើងនឹងបន្ថយកំដៅយ៉ាងទៀងទាត់ម៉ោងរបៀបនេះ គេអាចបញ្ជាបានដោយប្រើ"Thermostart"ដែលជាឧបករចាំបាច់មួយ នាបច្ចុប្បន្នងាយស្រួលតម្លើងនឹងអាចសន្សំលុយបានដែរ នៅពេលដែលថ្លៃភ្លើង"អគ្គីសនី"កំពុងតែឡើងថ្លៃមិនឈប់។



# សម រង្ស៊ី បន្ថែមល្បឿនដំណើរទៅរកការបែកបាក់ផ្ទៃក្នុង

ដោយ ពិន សំខុន

តាំងតែពីចុងឆ្នាំ២០១៧ ក្រុមគណបក្សប្រឆាំង ដែលបានចេញមកក្រៅប្រទេស បន្ទាប់ពីត្រូវបានរំលាយចោលដោយគណបក្សប្រជាជនកម្ពុជារួចមក បានខិតខំប្រឹងតស៊ូយ៉ាងអស់សង្ឃឹម ធ្វើជាក្បាលម៉ាស៊ីនដឹកនាំការប្រឆាំងនឹងរបបលោកហ៊ុន សែន គ្រប់ច្រកល្ហកនៃពិភពលោក តាមរបៀបធ្វើបាតុកម្ម ប្រើពាក្យសម្តីឃោសនា ខិតខំកៀងគរមនុស្ស បង្ហាញកម្លាំងទៅ"ភ្នំពេញ" នឹងទៅសហគមន៍អន្តរជាតិថា "ខ្មែរនៅក្រៅប្រទេសនៅមូលគ្នាប្រកបដោយកម្លាំង មានគ្នីគ្នាគ្រប់គ្រាន់អាចនឹងយកអំណាចពីរបបប្តេចការមកវិញក៏បាន ។

លោកអតីតសហប្រធានគណបក្សសង្គ្រោះជាតិ សម រង្ស៊ី បានប៉ុនប៉ងត្រឡប់មកយកអំណាចក្នុងគណបក្សប្រឆាំងដោយជៀសវាងមិនប្រើឈ្មោះគណបក្សសង្គ្រោះជាតិបណ្តាលឱ្យក្រុមអ្នកប្រឆាំងនឹងរបបភ្នំពេញ បែកបាក់គ្នាយ៉ាងដំណំដោយសារតែមានអ្នកគាំទ្រជាច្រើន មិនចង់ឱ្យបាត់ឈ្មោះហើយចាកចេញពីគណបក្សសង្គ្រោះជាតិ"ដើម" ដែលធ្លាប់តែល្បីល្បាញ។ ឥឡូវក្រុមលោក សម រង្ស៊ី អមដោយលោកស្រី ជូឡុង សូមូរ៉ា លោក អេង ឆាយអៀង លោកស្រី មួរ សុខហួរ នឹងតំណាងរាស្ត្រ ៣-៤រូបទៀត មានឈ្មោះថា "ចលនាសង្គ្រោះជាតិ" ឬបន្ទាប់មកមានឈ្មោះថា "គណបក្សសង្គ្រោះជាតិអាមេរិកា" មិនអាចចូលរួមគ្នានឹងក្រុមម្ខាងទៀតបានទេ ជាក្រុមគាំទ្រគណបក្សសង្គ្រោះជាតិមានកូនស្រីលោក កឹម សុខា រួមគ្នានឹងលោកដំណាងរាស្ត្រ យ៉ែម ប៉ុញ្ញារិទ្ធ ជាជំហ៊រ ។

គ្មាននរណាបានដឹងឱ្យបានច្បាស់លាស់ថា "ការបាក់បែកគ្នានោះមកពីចំណុចអ្វីនោះទេ!" ហើយក៏គេមិនមានការច្បាស់ក្នុងចិត្តថា "លោក កឹម សុខា ដែលនៅជាប់ឃុំឃាំងនៅក្នុងផ្ទះរបស់លោកនោះ មិនច្បាស់ជាមានជំហ៊រនៅខាងណានោះដែរ "។ គេរឹតតែមិនដឹងថា សកម្មភាពរបស់ក្រុមទាំង២ នឹងមានទិសដៅ"អនាគតនយោបាយ"ជាយ៉ាងណានោះទេ គេគ្រាន់តែដឹងថា ក្រុមលោក សម រង្ស៊ី - អេង ឆៃអៀង - ជូឡុង សូមូរ៉ា កំពុងតែប្រមូលគៀងគរមនុស្ស ត្រៀមធ្វើមហាសន្និបាទនៅ"អាតាឡងតា"ដើម្បីប្តូរក្បាលម៉ាស៊ីនដឹកនាំ -ផ្ទុយគ្នានឹងក្រុមកញ្ញា កឹម មនោវិទ្យា នឹង ពៀម ប៉ុញ្ញារិទ្ធ ច្រើនធ្វើសកម្មភាពកិច្ចការបរទេស ជាមួយប្រទេសមហាអំណាច ហើយនៅស្ងាប់ស្ងៀម មិនព្រមចុះចូលនឹងក្រុម សម រង្ស៊ី ទេ ដោយគេមិនទុកចិត្តថា"ក្រុម សម រង្ស៊ី អាចនឹងប្តេជ្ញាចិត្តថានឹងទៅចូលតុចរចារជាមួយភ្នំពេញថ្ងៃណាមួយ!" ។

នៅឡូវែលមាន"ចលនាផ្តាច់ក្បាល"បានកើតឡើង ក្រុមលោក សម រង្ស៊ី យកបាន រឹទ្ធី អ៊ុង - សុខផល ប៉ែន - ម៉ែន វណ្ណ បានធ្វើសកម្មភាពកំដរ"ចលនា"ស្ទើររាល់សប្តាហ៏, តែ"ក្រុមឥតក្បាល" ក្រាញមិនព្រមស្លាប់ ឬចុះចូល ដោយអ្នកនៅសល់លំដាប់ថ្នាក់បន្ទាប់ បានក្រោក"គ្រវីទុងបក្ស"បន្តទៅទៀតទន្ទឹមគ្នាយ៉ាងក្លាហាននឹងស្ងៀមស្ងាត់។

នៅប៉ារីសនៃប្រទេសបារាំងវិញ ដែលជាមូលដ្ឋានលោក សម រង្ស៊ី - សូមូរ៉ា ជូឡុង ទីនោះច្រើនជាអ្នកអភិរក្សនិយមជាអ្នកគោរពច្បាប់ទម្លាប់ច្រើនជាងចង់ធ្វើនយោបាយ មាន ហម ប៊ុនឆាយ ជាប្រធាន មិនបាន"ដាច់ក្បាល"ចេញពីក្រុមគាំទ្រសង្គ្រោះជាតិទេ -គេបានចេញសេចក្តីថ្លែងការមួយថា"ការធ្វើសន្និបាទពិភពលោក របស់ក្រុម សម រង្ស៊ី ដើម្បីប្តូរក្បាលម៉ាស៊ីនសង្គ្រោះជាតិ ខែធ្នូ ២០១៨នេះ គឺជាប្រភពនៃការបែកបាក់ផ្ទៃក្នុង ពីព្រោះក្រុមលោក សម រង្ស៊ី ធ្វើដោយមិនគោរពតាមលក្ខន្តិកៈ នឹងសេចក្តីសម្រេចរបស់គណកម្មការនាយក ដែលបានធ្វើមុនពេលត្រូវគេរំលាយបក្សនោះទេ"។



លោក សម រង្ស៊ី អតីតប្រធានគណបក្សសង្គ្រោះជាតិ

ហេតុអ្វីបានជាក្រុម សម រង្ស៊ី សម្រេចចង់យក"ការបែកបាក់"ជាងការសម្រុះសម្រួល "រួមកម្លាំង"គ្នា? គេអាចយល់បានថា សម រង្ស៊ី ត្រូវការឯករាជ្យភាព ដើម្បីងាយស្រួលធ្វើសេចក្តីសម្រេចចិត្តអ្វីមួយដោយមិនចាំបាច់មើលទឹកមុខនរណានោះទេ។ដំណើរនេះ ឆ្ពោះទៅរកការត្រឡប់ក្រោយបង្កើតអង្គភាពអ្វីមួយដែលថ្មីមិនមានទាក់ទងនឹងសម្ព័ន្ធភាពចាស់ ហើយដែល សម រង្ស៊ី អាចធ្វើជាមេកើយស្របច្បាប់តែម្នាក់ឯង ដូចកាលនៅជា"គណបក្ស សម រង្ស៊ី"ដូច្នោះដែរ។ គេក៏អាចនិយាយពន្យល់បានម្យ៉ាងទៀតថា"ក្រុមគាំទ្រគណបក្សសង្គ្រោះជាតិ"ដែលជាស្លាបម្ខាងទៀតនោះក៏ត្រូវត្រឡប់ទៅរកមេកើយខ្លួនឯងម្នាក់ទៀតមកគ្រប់គ្រងជំនួសលោក កឹម សុខា ដែលនៅជាប់ឃុំឃាំងនោះទៅ ហើយឈប់ទិទានក្រុម សម រង្ស៊ី តទៅទៀត។ ស្របពេលដែលអតីតសង្គ្រោះជាតិកំពុងតែប្រជែងនឹងខ្លួនឯងភ្នំពេញឯណោះក៏ប្រជែងនឹងអំពើពុករលួយ គ្រួសារនិយម លក់ខ្លួនបំរើឱ្យបរទេសយ៉ាងពេញទំហឹងខ្លាំងណាស់ដែរ... តាមមើលទៅគ្មានអ្វីមកជួយកម្ពុជាទាន់ទៀតទេ។



តមកពីទំព័រទី ០១

# អង្គការ"Barr-Klarman"វិនិយោគ...

រោងល្ខោននា៤0ឆ្នាំកន្លងមកនេះ ។

ដើម្បីឱ្យយល់ច្បាស់អំពីគុណប្រយោជន៍នៃមូលនិធិជំនួយដែលនឹងមានតួរនាទីបំរើសិល្បៈនឹងល្ខោនក្នុងសហគមន៍យើង យើងបានតាំងសំនួរមួយចំនួនដល់ Bonnie Butkard ជានាយកប្រតិបត្តិរបស់"រោងល្ខោនម៉េរីម៉ាក-MRT"ដែលមានចម្លើយដូចតទៅ:

១-តើ MRT ធ្វើរបៀបណាដើម្បីអ្នកអានគេលើកដំកើងវិស័យល្ខោនឱ្យប្រសើរឡើងបាន?

MRT នឹងបន្តរផលិតការងារដែលឆ្លុះបញ្ចាំងពីពលរដ្ឋពហុសាស្ត្រក្នុងសហគមន៍ គឺនៅក្នុងសាច់រឿងក្នុងអត្ថន័យនឹងបុគ្គលិក... ដូចជាកាលពីឆ្នាំមុនយើងបានលើកយករឿងរបស់ វិចិត្រ ជុំ សិល្បៈសម្តែងតែម្នាក់ឯងពីបទពិសោធន៍នៃ"ខ្មែរ-អាមេរីកាំង"។ ឆ្នាំនេះ វិចិត្រ ជុំនឹងត្រឡប់មកវិញជាមួយនឹងល្ខោន២រឿង Miss Bennet "" Christmas at PemberLey" នឹង "The Haunted Life "។ យើងជឿជាក់ថា រឿងនេះនឹងប៉ះពាល់យ៉ាងជ្រាលជ្រៅដល់អារម្មណ៍អ្នកមើល ដែលបានឃើញរឿងខ្លួនឯងផ្ទាល់នៅលើឆាកនៅលើអ្នកសម្តែងនឹងបង្កើតការសម្តែងរឿង ដែលកើតឡើងនៅ "វិមានសេរីភាព"។ នៅក្នុងសាច់រឿង"The Haunted Life"ដោយ Jack Kerouac តួរសម្តែងមានបញ្ហានឹង "សង្គ្រាម-អន្តោប្រវេសន៍ -ប្រកាន់សាសន៍ "ការប្រទូស្តរាយដែលត្រូវរំកិលរវាង"វណ្ណៈ"ហើយនឹងក្តីសង្ឃឹមជាមួយនឹងការជានាគ្នារវាង"ជំនាន់និមួយៗ"...ជាប្រធានបទដែលកើតតាំងពី១៩៤0ឥឡូវនៅតែរស់រវើកនៅឡើយ ។

២-ជាមួយនឹងមូលនិធិជំនួយ The Barr-Karman តើជំរើសណាមួយដែល MRT អាចនឹងផ្តល់ឱ្យដល់ពលរដ្ឋពហុសាស្ត្រក្នុងន័យជាអ្នកមើលនឹងកម្មវិធី?

អង្គការ"ណែនាំវិស័យសិល្បៈរដ្ឋម៉ាសាឈូសិ តBarr-Klarman"នឹងជួយឱ្យ MRT មានការទ្រទង់ខាងហិរញ្ញវត្ថុហ្នឹងហ្នជាងមុន ដែលនេះជាធនធានសម្រាប់ឱ្យយើងផ្តោតអារម្មណ៍ទៅលើគោលបំណងដ៏រឹងមាំ, ពហុលក្ខណៈ ភាពចុះចូលក្នុងសង្គម អង្គការ"ណែនាំវិស័យសិល្បៈរដ្ឋម៉ាសាឈូសិតពារវ-Klarman"ហើយនឹងបេសកកម្មដើម្បីបង្កើតរឿងថ្មីៗទៀត ។ ថវិការសេវាពិគ្រោះយោបល់ ដែលមកជាមួយគម្រោងយុទ្ធសាស្ត្រនឹងក្លាយជាជំនួយដល់ផែនការយ៉ាងមាំដែលនឹងផ្តល់ឱ្យការងាររបស់យើងជ្រួតជ្រាបទៅដល់សហគមន៍ទាំងមូលបាន ។

អង្គការចំនួន២៩ មកពីម៉ាសាឈូសិតទាំងមូល ដែលនឹងទទួលមូលនិធិពីអង្គការ"ណែនាំវិស័យសិល្បៈរដ្ឋម៉ាសាឈូសិតពារវ-Klarman" ដែលដំណាងឱ្យពហុលក្ខណៈនៃវិស័យសិល្បៈមាន:

• Academy of Music Theatre (Northampton)




• A Far Cry (Boston)

• Barrington Stage Company (Pittsfield)

• Boston Chinatown Neighborhood Center (Boston)

• Boston Modern Orchestra Project (Malden)

• Cape Ann Museum (Gloucester)

• Community Access to the Arts (Great Barrington)

• Community Art Center (Cambridge)

• Community Music School of

Continued to Page 08

# The Barr-Klarman Massachusetts Arts Initiative Awarded $25 Million In 29 Arts And Cultural Organizations

By Soben Pin
Email: sobenpin@khmerpost.us

The Barr-Klarman Massachusetts Arts Initiative recently announced a $25 million investment in 29 arts and cultural organizations from across Massachusetts to help strengthening the artistic programming that engages diverse artists and audiences.

Amongst the grant recipients, Lowell's Merrimack Repertor Theatre has received $450,000 —making it the largest foundation grant in the theatre's 40 years history.

To better understand how this foundation grant will play a role in our art and theater community, we asked Bonnie Butkas, the Executive Director of the MRT a couple questions and here are her responses:



Bonnie Butkas

*How is MRT making the theater more relevant to our readers?*

Bonnie: MRT continues to produce work that reflects the diversity of our community in casting, content, and staffing. For example, last year we produced Vichet Chum's one-person show about his experience as a Cambodian American. This year Vichet returns to our stage in two plays: Miss Bennet: Christmas at Pemberley and The Haunted Life. We believe that it's profoundly impactful for people to see themselves on our stages, on our staff, and creating the plays you see at Liberty Hall. In our adaptation of The Haunted Life by Jack Kerouac, the characters struggle with war, racism, immigration, the struggle to move from between classes, and the hope of reconciliation between generations. Set in the 1940s, these themes are still relevant today.

*With the Barr-Klarman foundation grant, in what ways MRT will able to engage in the diversity of the audience and programs?*

Bonnie: The Barr Klarman Massachusetts Arts Initiative grant will enable MRT to become more financially stable and give us the tools and resources to focus on our goals of greater Equity, Diversity and Inclusion and our mission of producing new plays. This funding, the consulting services that come with it, and our new strategic plan, will help us build a solid plan to make our work relevant and accessible to our entire regional community.




Vichet Chum's Feature Play In 2017-2018 Season at MRT/KhmerPost USA File

The 29 organizations from across Massachusetts which received the Barr-Klarman Massachusetts Arts Initiative grants for representing diversity across artistic disciplines, geographic reach, stages of organizational development, and budget sizes are:

• Academy of Music Theatre (Northampton)

• A Far Cry (Boston)

• Barrington Stage Company (Pittsfield)

• Boston Chinatown Neighborhood Center (Boston)

• Boston Modern Orchestra Project (Malden)

• Cape Ann Museum (Gloucester)

• Community Access to the Arts (Great Barrington)

• Community Art Center (Cambridge)

• Community Music School of Springfield (Springfield)

• Company One Theatre (Boston)

• The Dance Complex (Cambridge)

•Design Museum Boston (Boston)

• Double Edge Theatre (Ashfield)

• Eliot School of Fine & Applied Arts (Boston)

Continued to Page 08





# DIVERSITY
## ADULT DAYCARE CENTER

*"A place where your loved ones can call home"*

**What is Adult Day Care:**
We understand that being a fulltime caregiver is a difficult job. When an elderly loved one needs additional care or supervision during the morning or day, it can create stress for the caregivers of the family. Many families think they have no choice but to quit their jobs or to admit their loved ones into a nursing home or assisted living facility. Diversity Adult Daycare Center (DADC) provides a safe supervised community where elderly adults can socialize, enjoy activities and get assistance with personal care. This will allow the caregivers of the family to have peace of mind when they have an appointment, work obligations or simply to enjoy some personal time.

**Benefits of Adult Day Care for Elderly Adults:**
Attending Adult Day Care has many positive benefits for elderly adults. Your loved ones do not have to be at home feeling lonely with no mental stimulation, when the caretakers are occupied. Being in an Adult Day Care creates a feeling of being in a community, where they can have fun and stay healthy with many activities. Your loved ones will look forward to having their independence and meeting their friends. Having friendships that you see every day promotes feelings of self-worth and camaraderie.

**Services we offer at DADC:**
- Nutritious meals and snacks
- Group fitness classes
- Education classes
- Group field trips and outings
- Fun daily entertainment and activities
- Assistance with personal care
- Salon service
- Transportation
- Monthly birthday parties
- Medical staff
- Gardening

**Who is an ideal candidate for Adult Day Care:**
- 55 years and older
- Southeast Asians & Hispanic
  (we are handicap accessible)

**Forms of payment that we accept:**
- We accept private pay
- All major insurances accepted

433 Elmwood Ave. Providence, R.I 02907
P: 401-427-1337 | F: 401-369-7818
www.diversityadc.com | diversityadc@gmail.com

**Se Habla Español**

We speak English, Spanish, Khmer, Lao, Hmong, Portuguese, Russian and Tagalog.
Come and schedule a free tour of our facility. We will provide free assessment and application assistance.
All major insurances and private pay accepted. Medicaid pays for adult day care, there is no cost to you.

# Thanksgiving ជាថ្ងៃអរគុណដល់ម្ចាស់ទឹកដីនៃសហរដ្ឋអាមេរិក

ដោយខ្មែរផុសស.រ.អា.

បុណ្យ"សាំងគីវីង"នឹងត្រូវប្រារព្ធជារៀងរាល់ថ្ងៃព្រហស្បតិ៍សប្តាហ៍ទី៤ នៃខែវិច្ឆិកានៅ រៀងរាល់ឆ្នាំ លើកនេះនឹងត្រូវប្រារព្ធនៅថ្ងៃទីព្រហស្បតិ៍ ២២ខាងមុខនេះហើយ ដែលគ្រួសារនិមួយៗ តែងធ្វើម្ហូប"មាន់ធើគី" ឬមាន់បារាំងដុតសម្រាប់ទទួល



ភ្ញៀវក្នុងគ្រួសារ ឬជាមិត្តជិតស្និត ។ ដើម្បីអបអរក្នុងពិធីនេះ -អង្គការមនុស្សធម៌ជាច្រើនតែងធ្វើអំណោយ"មាន់ធើគី"នេះដល់គ្រួសារ ដែលមានចំណូលតិចតួចឱ្យអាចជប់លៀងក្នុងគ្រួសារបានយ៉ាងអ៊ឹកធឹកបានដែរ ។

ប្រវត្តិសាស្ត្រនេះបានផ្តើមនៅឆ្នាំ១៦១៤ នៅពេលដែលពួកស្វែងរកទឹកដីថ្មី សម្រាប់រស់នៅហៅ"ផែលក្រីម"មកពីប្រទេសអង់គ្លេស-អាល្លឺម៉ង់ តាមសំពៅ បានមកដល់រដ្ឋម៉ាសឈូសិត រដ្ឋកូណិកទីកិត គេបានជួបនឹងពួក(ភ្នង) ម្ចាស់ស្រុកដែលពួកគេបានបង្ហាត់បង្ហាញរបៀបដាំពោតចិញ្ចឹមមាន់ទាដែលជាប្រភពម្ហូបដ៏សំខាន់សម្រាប់ពលរដ្ឋ... ១ឆ្នាំក្រោយមក ក៏បានផលជាទីគាប់ចិត្តគេក៏នាំគ្នាធ្វើពិធីបុណ្យដ៏ធំមួយសម្រាប់រំលឹកពិការបានជួបជុំគ្នាបង្កើនផលកសិកម្មជាមួយភ្នងម្ចាស់ស្រុកនៅលើទឹកដីដ៏មានជីជាតិ ។

ដំណឹងនេះ បានឮសុះសាយនៅប្រទេសអឺរ៉ុប ដែលក្រុមដដែលនេះ បាននាំគ្នាមកកាន់ទឹកដីពួងភ្នងនេះកាន់តែច្រើនឡើង ហើយពិធីបុណ្យ"សាំងគីវីង"នេះ បានត្រូវប្រារព្ធឡើងនៅច្រើនកន្លែងនៃពេលបន្ទាប់មក -ច្រើនឆ្នាំក្រោយមក ទើបប្រធានាធិបតី"អាប្រាហាម លីនខិន"ប្រកាសថាជាបុណ្យជាតិ ។

ប៉ុន្តែនៅមានផ្នែកនៃប្រវត្តិសាស្ត្រដែលគេមិនសូវសរសេរ ដែលជាផ្នែកដ៏អាម៉ាសរបស់សហរដ្ឋអាមេរិកនោះ គឺការវាតយកទឹកដីថ្មីរបស់ពួកស្បែកស ដោយការកាប់សម្លាប់ពួកភ្នងម្តងៗ ជាច្រើនរយនាក់ ទុកតែអ្នកមាំមួន មានកម្លាំងកំហែងធ្វើជា"ទាសករ"ប៉ុណ្ណោះចាប់ដាក់សំពៅទាំងរយនាក់យកទៅលក់នៅតំបន់ផ្សេងៗ ដែលត្រូវការកម្លាំងពលកម្ម។ អ្នកប្រវត្តិសាស្ត្រខ្លះសរសេរថា"បុណ្យសាំងគីវីង"នេះ តែងតែធ្វើបន្ទាប់ពីពេលដែលពួក"ផែលគ្រីន"យកបានជ័យជំនះ លើទឹកដីពួកម្ចាស់ដី ដែលជាភ្នងក្នុងតំបន់សម្លាប់ក្មេងៗនឹងស្ត្រីខ្មៅរង្គាលដុតក្នុងភ្នក់ផ្ទះទាំងរស់អស់ គេទុកប្រុសៗធ្វើជាទាសកររួច ទើបគេនាំគ្នាធ្វើបុណ្យនោះ។

បុណ្យ"សាំងគីវីង"នេះ ក៏ជាមេរៀនដ៏ថ្លៃថ្លាសម្រាប់ប្រជាពលរដ្ឋថ្មីនៃសហរដ្ឋអាមេរិក ដែលបានមកដល់ដែនដីនៃសេរីភាព តែទឹកដីដើមរបស់ខ្លួនបានត្រូវជនជាតិដ៏ទៃដណ្តើមយកដោយកម្លាំងបាយនឹងដោយកម្លាំងប្រាជ្ញមិនអាចឱ្យអ្នកដែលនៅសល់លើទឹកដី អាចរស់ជាម្ចាស់ស្រុកនៅដោយសុខសាន្តបានឡើយ ។

# ថ្ងៃសុក្រខ្មៅ "Black Friday"

ថ្ងៃសុក្រខ្មៅ "Black Friday" បន្ទាប់ពី "សាំងគីវីង"បន្ទាប់ពីថ្ងៃឈប់សម្រាក"សាំងគីវីង" ១ថ្ងៃ គឺថ្ងៃសុក្រខ្មៅ ដែលគេហៅថា"Black Friday"ជាថ្ងៃដែលមនុស្សជ្រួលច្របល់រត់ទៅហាងលក់ឥវ៉ាន់ចុះថ្លៃពិសេសប្រចាំឆ្នាំ។ ពាណិជ្ជករធំៗជាច្រើន បានសម្រេចព្រមគ្នាថា យកថ្ងៃ២៣វិច្ឆិកា លក់ទំនិញទាំងអស់បញ្ចុះថ្លៃពិសេសជាងពេលណាទាំងអស់ប្រចាំឆ្នាំតែម្តង ដែលជាហេតុធ្វើឱ្យថ្ងៃនេះ មានប្រជាប្រិយភាពអស្ចារ្យធ្វើឱ្យមនុស្សចេញមកទិផ្សារ ដូចគ្នានឹងថ្ងៃបុណ្យធំមួយដែរ។




ហេតុអ្វី?

១-នាចុងបញ្ចប់នៃឆ្នាំនិមួយៗទំនិញទាំងអស់ត្រូវប្តូរថ្មី សម្រាប់ឆ្នាំថ្មីៈ មានឈុតខោអាវប្រុសស្រី មានលក់របស់របរប្រើប្រាស់ក្នុងផ្ទះ មានទាំងលក់រថយន្ត ...។ល។ ដូច្នេះការបញ្ចុះថ្លៃនេះអាចនឹងបង្ហូរទំនិញឆ្នាំចាស់ចេញពីហាងបានយ៉ាងងាយស្រួលត្រៀមដាក់ឥវ៉ាន់ឆ្នាំថ្មីចូលមកជំនួសវិញ ធ្វើដូច្នេះក៏អាចធ្វើឱ្យមាន"លុយសុទ្ធ"សម្រាប់ពាណិជ្ជកម្មបន្តទៅទៀតដែរដែរ។

២-សម្រាប់សាធារណជន នាឱកាសចុងឆ្នាំជាឱកាសដែលត្រូវចំណាយលើ"អំណោយ"សម្រាប់កុមារ នាឱកាស"Chrismas -New Year" សម្រាប់ជូនបងប្អូនសម្រាប់ជូនមិត្តភក្រ្តដ៏ច្រើន ដូច្នេះគេត្រូវការណាស់នូវទំនិញល្អៗ ដែលចំណាយប្រាក់តិច ហើយបានរបស់ច្រើន... ដូច្នេះ"Black Friday" គឺជាឱកាសបំពេញវត្ថុបំណងរបស់សាធារណជននោះបានហើយ ។

"ថ្ងៃសុក្រខ្មៅ"បង្កើតឡើងដោយក្រុមពាណិជ្ជករ ក៏ពិតមែនតែឥឡូវនេះបានក្លាយជាវប្បធម៌មានប្រយោជន៍សាធារណទៅហើយ ពីព្រោះមនុស្សកាន់តែច្រើន អាចចែករំលែកធ្វើទានចំពោះអ្នកដ៏ទៃ បានកាន់តែពាសពេញប្រទេសប្រកបដោយសទ្ធាជ្រះថ្លា។ដូច្នេះហើយ មិនថា ក្រឬមានទាំងអស់គ្នាមានលទ្ធភាពនឹងចូលរួមបុណ្យ"គ្រីស្ត្រមើស"បានយ៉ាងពេញចិត្ត។

កម្មវិធីថែទាំសុខភាពសម្រាប់មនុស្សពេញវ័យរបស់គម្រោង អល ខែរីសស (All Care Resources) ត្រូវបានបង្កើតឡើងក្នុងគោលបំណងដើម្បីជួយដល់អ្នកជំងឺ និងអ្នកថែទាំដែលរស់នៅជាមួយគ្នានៅក្នុងសហគមន៍តាមរយៈការផ្តល់នូវការគាំទ្រផ្នែកវេជ្ជសាស្ត្រ, ការអប់រំ និងប្រាក់កម្រៃ។

លក្ខខណ្ឌនៃការដាក់ពាក្យក្នុងកម្មវិធីនេះ :

-អ្នកដែលមានជំងឺត្រូវមានអាយុ១៦ឆ្នាំនិងច្រើនជាងនេះ ហើយត្រូវការការថែរក្សានិងការមើលការខុសត្រូវសម្រាប់សកម្មភាពនៃការរស់នៅប្រចាំថ្ងៃ និងត្រូវមានស្តង់ដាម៉ាស់ហែល។

-អ្នកថែទាំត្រូវមានអាយុយ៉ាងហោចណាស់១៨ឆ្នាំ " រស់នៅក្នុងផ្ទះជាមួយនឹងអ្នកជំងឺតែអ្នកមើលថែនោះមិនត្រូវជាប្រពន្ធ រឺស្វាមី, អ្នកទទួលសិទ្ធជាអាណាព្យាបាលស្របច្បាប់របស់អ្នកជំងឺ ឬជាឪពុកម្តាយដែលមានកូនមិនទាន់ពេញវ័យនោះទេ។

-អ្នកថែទាំ និងអ្នកជំងឺត្រូវតែរស់នៅជាមួយគ្នា ហើយអ្នកថែទាំត្រូវតែមានលទ្ធភាពមើលថែអ្នកជំងឺពេញ២៤ម៉ោងក្នុង៧ថ្ងៃក្នុងមួយសប្តាហ៍។

ប្រសិនបើអ្នកមានចំណាប់អារម្មណ៍ សូមទំនាក់ទំនង លីនា ឌៀប (Lyna Dep) ដែលស្ទាត់ជំនាញភាសាខ្មែរ តាមរយៈលេខទូរស័ព្ទ ៧៨១-២៨៤-១១១៥ ។

ការិយាល័យ មេធាវី ចំមាស ស្តាលីយ៉ាណូស

Law Office of Thomas Stylianos Jr.
287 Appleton St. Lowell MA 01852

- Immigration • អន្តោប្រវេសន៍
- Auto Crash • គ្រោះថ្នាក់រថយន្ត
- Divorce • លែងលះប្តីប្រពន្ធ

សូមទាក់ទង សោភា ឬ ធំ 978-459-5000 or 800-308-3766
www.thomasinlowell.com


Boch Honda West
299 Littleton Rd, Westford, MA 01886
EXIT 32 - OFF 495
Happy Honda Days
SALES EVENT
ធ្វើដំណើរជុំវិញពិភពលោក ៨ ដង
ហើយលោកអ្នក
នៅតែមានការការពារ
HOME OF THE
20 YEAR
200,000 MILE
LIMITED POWERTRAIN
★ WARRANTY ★
BOCH Honda West
HONDA
រួមបញ្ចូលជាមួយនឹងរាល់ការ
ទិញរថយន្តហុងដា ថ្មី
ដោយមិនគិតថ្លៃបន្ថែមទៀតឡើយ !
ធានាមានរថយន្តថ្មីនៅក្នុងស្តុក លើកលែងតែម៉ូដែលដាក់លក់មួយចំនួនប៉ុណ្ណោះ
ហើយការធានាគឺមិនអាចផ្ទេរបានឡើយ។ មិនមានសម្រាប់ជួល។
ច្បាប់ចម្លងលិខិតធានាមានសម្រាប់អតិថិជនមើលនៅកន្លែងលក់។
HONDA
មានវិញ្ញាបនបត្រ
ផ្តល់សិទ្ធធ្វើជាម្ចាស់ជាមុន
ផ្តល់ជាពិសេសសម្រាប់ធ្វើជាម្ចាស់ជាមុន
2015 Honda ACCORD LX VIN: FA250832 $13,478
2017 Honda CIVIC LX VIN: HE077504 $16,298
2006 Mitsubishi ECLIPSE VIN: 6E014386 $6,495
2012 Nissan ROGUE VIN: CW714281 $8,974
2016 Honda CIVIC EX VIN: GH524634 $16,324
2014 Honda CRV EX-L VIN: EH652299 $16,998
2016 Toyota CAMRY LE VIN: GR534026 $12,997
2009 Jeep WRANGLER VIN: 9L759321 $14,995
2015 Honda CRV EX VIN: FH698891 $19,447
2017 Honda ACCORD SPORT VIN: HA271711 $19,688
2015 Mazda CX5 VIN: F0449392 $15,996
2017 Nissan FRONTIER V6 VIN: HN759961 $22,888
2015 Honda PILOT EX VIN: FB018561 $21,283
2016 Honda PILOT EX VIN: GB029483 $24,685
2016 Acura MDX W/TECH VIN: GB045640 $30,948
2015 BMW 640I XDRIVE CONVERTIBLE VIN: FD873174 $39,984
BochHondaWest.com
រាល់តម្លៃដែលបានផ្សព្វផ្សាយ មិនរួមបញ្ចូលពន្ធ និងការបង់ថ្លៃផ្សេងៗដល់រដ្ឋាភិបាល, ការចំណាយលើការរត់ការទទួលឥណទាន, ការបង់លើការរៀបចំឯកសារទិញលក់, បង់ថ្លៃ
រៀបចំឯកសារបង់ពន្ធតាមប្រព័ន្ធអេឡិចត្រូនិច និងការបង់ថ្លៃលើការធ្វើតេសការបំភាយឧស្ម័នរបស់រថយន្ត។ ការផ្តល់ជូននេះ ផុតកំណត់ថ្ងៃទី 9 ខែធ្នូ ឆ្នាំ 2018។
សម្រាប់ព័ត៌មានបន្ថែម
សូមទំនាក់ទំនង នីកូល ឈុន: nchhun@bochhondawest.com
ត្រូវការបុគ្គលិកផ្នែកលក់ !
ទំនាក់ទំនងមកកាន់ ខេវិន វេជ: kcregg@bochhondawest.com
BochHondaWest.com | (978) 252-2125
HONDA

# Girls Inc. celebrates “smart, strong & bold” women

By Irene Egan, Contributor Writer

As part of celebrating its 100th year of service, Girls Inc. of Greater Lowell recently unveiled a new granite bench in front of its location on Worthen Street. The dedication ceremony was held this month.

The bench is engraved with the names of 108 women, both living and deceased, and includes local volunteers as well as national figures such as Oprah Winfrey. Each name was sponsored, with the proceeds adding to the Girls Inc. endowment fund for the future.

“With the endowment providing strong financial stability, we’re confident that we can continue to open opportunities for girls for the next 100 years,” said Sue LaRoche, Girls Inc. Board of Directors President.

More information about the agency’s programs for girls is available at 978-458-6529 or www.girlsinclowell.org.




# អង្គការហ្គើល អ៊ីន ប្រារព្ធកម្មវិធីស្ត្រីឆ្លាត វៃ, រឹងមាំ និងក្លាហាន

ជាផ្នែកមួយនៃការប្រារព្ធពិធីគម្រប់១០០ ឆ្នាំនៃប្រត្តិបត្តិការរបស់ខ្លួន អង្គការហ្គើល អ៊ីន (Girls Inc.) ឡូវែល កាលពីពេលថ្មីៗនេះ បាន




ដាក់បង្ហាញនូវប្រភេទកៅអីថ្មក្រានីតថ្មីនៅមុខទីតាំងរបស់វានៅលើផ្លូវវើសស្ទន។ កម្មវិធីបរិច្ចាគនេះត្រូវបានធ្វើឡើងនៅក្នុងខែនេះ។

កៅអីនេះ មានដាក់ឈ្មោះស្ត្រីចំនួន១០៨ នាក់ដែលទទួលមរណភាពហើយ និងនៅរស់ ហើយរួមបញ្ចូលទាំងអ្នកស្ម័គ្រចិត្តក្នុងស្រុក ព្រមទាំងស្ត្រីឆ្នើមថ្នាក់ជាតិជាច្រើនទៀតក៏ដូចលោកស្រី អប់រា វីនហ្វ្រី (Oprah Winfrey) ជាដើម។ ឈ្មោះនិមួយៗដែលមាននៅកៅអីត្រូវបានឧបត្ថម្ភដោយមានការចូលជាមូលនិធិបន្ថែមដល់អង្គការអង្គការហ្គើលអ៊ីនសម្រាប់ប្រើប្រាស់សម្រាប់ពេលអនាគត។

លោកស្រី ស៊ូ ឡារ៉ូស ប្រធានក្រុមប្រឹក្សាភិបាលរបស់អង្គការហ្គើល អ៊ីន បានមានប្រសាសន៍ថា “ជាមួយការបរិច្ចាគដែលផ្តល់ឱ្យមានស្ថិរភាពរឹងមាំផ្នែកហិរញ្ញវត្ថុ យើងមានទំនុកចិត្តថា យើងអាចបន្តបើកឱកាសសម្រាប់ស្ត្រីជាច្រើនក្នុងរយៈពេល ១០០ ឆ្នាំទៅមុខ”។

ព័ត៌មានបន្ថែមអំពីកម្មវិធីរបស់ទីអង្គការហ្គើលអ៊ីនចំពោះស្ត្រីអាចទំនាក់ទំនងតាមលេខទូរស័ព្ទ ៩៧៨-៤៥៨-៦៥២៩ ឬវ៉ិបសាយ www.girlsinclowell.org .

តមកពីទំព័រទី ០២

## អង្គការ “Barr-Klarman” វិនិយោគ...

Springfield (Springfield)

- Company One Theatre (Boston)
- The Dance Complex (Cambridge)
- Design Museum Boston (Boston)
- Double Edge Theatre (Ashfield)
- Eliot School of Fine & Applied Arts (Boston)
- Featherstone Center for the Arts (Martha's Vineyard)
- Fitchburg Art Museum (Fitchburg)
- Mahaiwe Performing Arts Center (Great Barrington)
- Merrimack Repertory Theatre (Lowell)
- New Bedford Art Museum/Art-Works! (New Bedford)
- New Bedford Symphony Orchestra (New Bedford)
- Norman Rockwell Museum (Stockbridge)
- Now + There (Boston)
- Payomet Performing Arts Center (North Truro)
- Provincetown Art Association and Museum (Provincetown)
- Raw Art Works (Lynn)
- The Record Co. (Boston)
- SpeakEasy Stage (Boston)
- Worcester Art Museum (Worcester)
- Zeiterion Theatre (New Bedford)

អង្គការទាំងនោះនឹងទទួលជំនួយច្រើនឆ្នាំ, មិនត្បិតត្បៀតលើជំនួយសម្រាប់បំរើការងារ - បន្ថែមពីនេះ តាមរយថវិការជំនួយពី TDC ដែលមានការទួលស្គាល់ទូទាំប្រទេសថា ជា “អង្គការផ្ត ល់យោបល់មិនយកកំរៃ - អង្គការទាំងអស់នឹងត្រូវចូលរួមក្នុងកម្មវិធីអប់រំ ផ្តោតទៅលើៈ មូលធន - សមត្ថភាពវប្បធមិ នឹងលទ្ធភាពសម្របសម្រួល។

ព័ត៌មានបន្ថែមពីសិល្បៈក្នុងតំបន់នឹងអង្គការវប្បធមិដែលទទួលបានមូលនិធីជំនួយ សូមចូលទៅៈ https://www.barrfoundation.org/what-we-do/barr-klarman-massachusetts-arts-initiative ។

Continued from page 04

## The Barr-Klarman Massachusetts...

- Featherstone Center for the Arts (Martha's Vineyard)
- Fitchburg Art Museum (Fitchburg)
- Mahaiwe Performing Arts Center (Great Barrington)
- Merrimack Repertory Theatre (Lowell)



Vichet Chum features at the MRT entrance

- New Bedford Art Museum/Art-Works! (New Bedford)
- New Bedford Symphony Orchestra (New Bedford)
- Norman Rockwell Museum (Stockbridge)
- Now + There (Boston)
- Payomet Performing Arts Center (North Truro)
- Provincetown Art Association and Museum (Provincetown)
- Raw Art Works (Lynn)
- The Record Co. (Boston)
- SpeakEasy Stage (Boston)
- Worcester Art Museum (Worcester)
- Zeiterion Theatre (New Bedford)

Organizations will receive multi-year, unrestricted operating grants. Additionally, through a grant to TDC, a nationally recognized nonprofit consulting and research group, organizations will participate in a learning program focused on capitalization, cultural competency, and adaptive capacity.

To learn more about your local art and cultural organization which received the foundation grant, visit: https://www.barrfoundation.org/what-we-do/barr-klarman-massachusetts-arts-initiative.

# វេជ្ជបណ្ឌិត សុខារិទ្ធិ ម៉ី
# DR. SOKHARITH MEY, MD



## ចាប់ផ្តើមទទួលអ្នកជំងឺថ្មី
## ទាំងពីរការិយាល័យឡូវែល & លីន

**Now Accepting New Patients at both Offices**
**Family Medicine & Behavioral Health**
**Please Call Us To Enroll:**

Flu shot and vaccinations available now at both offices
ពេលនេះមានចាក់ថ្នាំការពារជំងឺផ្តាសាយធំ និងវ៉ាក់សាំងនានាទាំងពីរទីតាំង

**Lowell - (978) 455-7992**
**Lynn - (781) 780-7755**

ផ្នែកជំងឺទូទៅ និងជំងឺផ្លូវចិត្ត

មណ្ឌលពិនិត្យសុខភាពឡូវែល
**Lowell Primary Care Center**
1075 Westford St. Unit 204
Lowell, MA 01851

មណ្ឌលពិនិត្យសុខភាពលីន
**Lynn Primary Care Center**
280 Union St. Unit 402
Lynn, MA 01901

បុគ្គលិកនិយាយភាសាខ្មែរ/ Staff speak Khmer
We accept MassHealth, Medicare and other health insurances

# "កញ្ឆា-Marijuana"ផ្ដើមឱ្យលក់រាយបាននៅរដ្ឋម៉ាសាឈូសិត

ខ្មែរផុសស.រ.អា.

ថ្ងៃអង្គារ ទី១៩វិច្ឆិកា កន្លងទៅ ជាថ្ងៃប្រវត្តិសាស្ត្រ ដែលរដ្ឋម៉ាសាឈូសិតផ្ដើមបើកទ្វារ អនុញ្ញាត្តិឱ្យលក់"កញ្ឆា"ដល់សាធារណជនអាយុច្រើន ជាង២១ឆ្នាំ ឡើងទៅហើយ។ កាលពី២ឆ្នាំនេះមុន សោះ"កញ្ឆា"គឺជាគ្រឿងញៀន តែនរណាប្រើប្រាស់ វា គឺខុសច្បាប់មានទោសជាប់ពិរុទ្ធជាមិនខានឡើយ -តែទោះជាយ៉ាងនេះក្ដីមានមនុស្សប្រើប្រាស់ "កញ្ឆា"នេះ ដោយលួចលាក់កាន់ច្រើនឡើងរាល់ថ្ងៃ ពីព្រោះគេជឿថា "ជក់កញ្ឆាបង្កើនអារម្មណ៏ល្អ បំបាត់ការចុកចាប់បង្កើនសុខភាពប្រសើជាងផឹកសុរាទៅទៀត..."រហូតដល់ក្លាយទៅជាស្របច្បាប់ទៅវិញនៅរដ្ឋខ្លះ៧នាពេលនេះ។








នៅសហរដ្ឋនេះ មានរដ្ឋចំនួន១០ដែលអនុញ្ញាត្តិឱ្យលក់នឹងជក់ជាសាធារណបានដូចគ្នានឹងជក់បារីដែរ(Marijuana for recreation use) ហើយក៏មានរដ្ឋចំនួន៣៣ទៀត ដែលបានទទួលអនុញ្ញាត្តិស្របច្បាប់ត្រឹមតែប្រើវា"ថ្នាំព្យាបាល -Medical Marjuana"វៃប៉ុណ្ណោះ។

នៅឡូវែលប្រជាពលរដ្ឋនិយាយថា"ពួកគេអាចដាំដើមកញ្ឆានៅផ្ទះបាន៦ដើម" ហើយមានអ្នកដើរលក់រាយដោយលួចលាក់ពីពេលមុននិយាយថា "ពីដើមសម្បូរភ្ញៀវ ហើយលក់បានថ្លៃទៀតឥឡូវស្រុតចុះអស់ហើយ ពីព្រោះនរណាក៏ដាំកញ្ឆាបានដែរ"។ មនុស្សជាច្រើនរីករាយណាស់ នៅពេលទទួលដំណឹងថា"អាចប្រើកញ្ឆាស្របច្បាប់"បានហើយនោះ។

នៅផ្សារ"ស្តុក-Stocks" គេអាចនៅទិញភាគហ៊ុន(តិចជាង៥0សេនក្នុង១ហ៊ុន) ក្នុងតម្លៃថោកនៅឡើយ តែមានការផ្សព្វផ្សាយថា"ភាគហ៊ុនអាចនឹងឡើងលឿនបាននៅពេលខាងមុខ"ដោយសារតែ"កញ្ឆា"មានគុណប្រយោជន៏ធំធេង តែច្បាប់មិនទាន់អនុញ្ញាត្តិគ្រប់គ្រាន់នៅឡើយ។

នៅប្រទេស"អុីស្រាអែល" គេឃើញសេដ្ឋកិច្ចប្រទេសនេះ បានត្រូវឈរនៅលើ"ឧស្សហកម្មកញ្ឆា"យ៉ាងខ្លាំងខ្លាជានយោបាយប្រទេស ហើយនាំថ្នាំ ឬផលិតផលសំអាងរូបរាងកាយ ធ្វើពីវត្ថុធាតុដើម"កញ្ឆា"ចេញក្រៅប្រទេសបានកាក់កបខ្លាំងណាស់ទៅហើយដែរ។









## ផ្តើមសេចក្តី

អារម្ភកថា

យើងសូមជូនរឿងថ្មីមួយទៀត គឺរឿង"កុមារ យោធិន្ទ"ជាប្រវត្តិកុមារប្រមាណជា១ពាន់នាក់ ដែលបានចូលទៅបំរើក្នុងកងទ័ពតាំងពិអាយុ១០ឆ្នាំ នៅសាលារៀនមួយដែលកងខេមរភូមិន្ទបាន បង្កើតឡើងបន្តពីអាណានិគមបារាំងក្នុងបំណងជួយចិញ្ចឹមកូនរបស់កងទ័ពបង្ហាត់បង្រៀនមុខវិជ្ជាដែល ឪពុករបស់គេស្រឡាញ់ចូលចិត្តនឹងបានបូជាជីវិត ដើម្បីមាតុភូមិរបស់គេថែមទៀត ។

ជារឿងពិតរបស់យុវជនមួយក្រុមរស់នៅដាច់ពីការថ្នាក់ថ្នមរបស់ឪពុកម្តាយមិនដូចក្មេង ឯទៀត គេចិញ្ចឹមកុមារទាំងនោះ ក្រោមវិន័យតឹងរឹងនៃកងទ័ពបង្ហាត់ហ្វឹកហ្វឺននឹងរៀនសូត្រវិជ្ជាចម្បាំងតាំងតែពីនៅតូច តែសាធារណជនមិនសូវដែលដឹងថា"សាលានោះជាអ្វី? បង្ហាត់បង្រៀនរបៀបណា? នឹងស្គាល់ថា ជាអ្វីនោះទេ" ក្រៅតែពីអ្នកនៅក្នុងក្រុងជាមួយនឹងអ្នកមិនឆ្ងាយពីបន្ទាយនៃកូនទាហ៊ានទាំងនោះ តែប៉ុណ្ណោះដែលស្គាល់ ហើយឱ្យឈ្មោះថា"ពួកក្មេងហ្វូង" ដែលជាឈ្មោះបកប្រែពីពាក្យបារាំងមកថា"Les enfants de troupe" ។

# ការរៀបចំរចនាសម្ព័ន្ធសាលាកុមារយោធិន្ទ(ត)

**ពិន សំខុន**

**ភាគ១ - សាលាកងកុមារយោធិន្ទ**

ពលឯក ចំនួន១២នាក់ សម្រាប់ជា អ្នកយាមបន្ទាយ ឬយាមប៉ុស្តិ៍ជាជំនួយការក្នុងផ្ទះបាយជា"អ័រដូណង់"របស់កុម៉ង់ដង់ -មានកាប៉ូរ៉ាល់ នឹងស៊ែហ្សង់៦នាក់ទៀត សម្រាប់គ្រប់គ្រងវិន័យនឹងកម្មវិធីប្រចាំថ្ងៃរបស់កុមារយោធិន្ទ -នឹងមាននាយទាហ៊ានរង៣នាក់ទៀតសម្រាប់កិច្ចការរដ្ឋបាល គឺ (OD លោកសក្តិ១ ស៊ីផៃ ) កិច្ចការសង្គមនឹងទទួលបញ្ជាផ្ទាល់ពីកុម៉ង់ដង់ (លោកអាត់ស៊ូ ដង់សែហ្វ អ៊ុន តាំងសេង) តែម្តង។

....មានកាប៉ូរ៉ាល់ នឹងស៊ែហ្សង់៦នាក់ទៀត សម្រាប់គ្រប់គ្រងវិន័យនឹងកម្មវិធីប្រចាំថ្ងៃរបស់កុមារយោធិន្ទ -នឹងមាននាយទាហ៊ានរង៣នាក់ទៀតសម្រាប់កិច្ចការរដ្ឋបាល គឺ (OD) កិច្ចការសង្គម នឹងទទួលបញ្ជាផ្ទាល់ពីកុម៉ង់ដង់(លោកអាត់ស៊ូដង់សែហ្វ អ៊ុន តាំងសេង) តែម្តង។

កម្មវិធីរាល់ថ្ងៃរបស់សិស្សកុមារយោធិន្ទ គឺរាល់ព្រឹក ត្រូវក្រោកដោយត្រែដាស់ៈ ពីម៉ោង៥,00 ដើម្បីហាត់ប្រាណ

ម៉ោង៦,00 ស្រស់ស្រូបពេលព្រឹក

ម៉ោង៧,00 ផ្លុំត្រែគោរពទង់ជាតិ

ម៉ោង៧:៣0 ចូលរៀន

ម៉ោង១១:00 ចេញពីរៀនថ្ងៃត្រង់

ម៉ោង១១:៣0 បាយថ្ងៃត្រង់

ម៉ោង ២ - ៤ រសៀល ចូលរៀនល្ងាច

ម៉ោង ៤ ហាត់ប្រាណ

ម៉ោង ៥កន្លះ បាយល្ងាច

ម៉ោង៧-៨កន្លះ ល្ងាចចូលរៀនផ្ទាល់ខ្លួន

ម៉ោង ៩យប់ ផ្លុំត្រែបិទភ្លើង - ដេក

ពេលកណ្តាលយប់ខ្លះ អាចនឹងត្រូវដាស់ឱ្យមកប្រជុំជួរ(ដោយការវាយជួង ឬ ផ្លុំត្រែប្រកាសអាសន្ន) ហៅឈ្មោះទាំងកណ្តាល


ទូត ចាន់ធួន អតីតកុមាយោធិន្ទ
កាលពី៥0ឆ្នាំមុន

អាធ្រាតសម្រាប់ឆ្មក់កុំឱ្យមានសិស្សណាលួចចេញទៅក្រៅសាលា ដោយមិនមានឱ្យដំណឹង ឬគ្មានសុំច្បាប់ -សិស្សទាំងអស់ត្រូវក្រោកទាំងសើងមម៉ើង រត់មកតម្រង់ជាជួរដោយមិនចាំបាច់ស្លៀកពាក់ឯកសណ្ឋាន នៅមុខកា-រិយាល័យនាយទាហ៊ាន ហើយត្រូវគេហៅអត្តលេខគ្រប់គ្នា - សែព ស៊ីម នឹងសែពសយ ច្រើនជាអ្នកចេញបញ្ជាឱ្យវាយជួង "អាលែក Alerte" សិស្សដែលអវត្តមាននៅពេលរាត្រីនោះនឹងទទួលទោសឱ្យធ្វើការធូន់ គេហៅថា (TC =tenue de campagne ) ។ សិស្សដែលមានទោសនោះ នឹងត្រូវពិន័យនាថ្ងៃសៅរ៍នឹងថ្ងៃអាទិត្យ(ជាថ្ងៃឥតមានសាលារៀន) ដោយឱ្យធ្វើការដកស្មៅ ឬលាងបង្គន់ ឬរត់ជុំវិញអាគារវែង ឬក៏ហាត់វិជ្ជាទាហ៊ានទាំងកណ្តាលថ្ងៃក្រៅ... ។ល ។

ទូត ចាន់ធួន អត្តលេខ៦១៩ មានបងប្អូន២នាក់ បងឈ្មោះ ទូត ចាន់ថន អត្តលេខ ៦១៨ ទាំង២នាក់បានចូលសាលាកុមារយោធិន្ទនៅឆ្នាំ១៩៥៩ ទៅពីភ្នំពេញឪពុកជាពលទោនៅទីនោះ ។ នាឆ្នាំដំបូងនោះ ពួកគេនៅក្នុងចំណោមពួកសិស្សថ្មីតូចៗ ដែលពួកសិស្សច្បងចូលចិត្តធ្វើបាប ខោកក្បាលលេងប្រើច្រងាប់ច្រងិល ហើយធ្វើឱ្យយំរាល់ថ្ងៃ... ក្រុមនោះ មាន ទ្រី សាយហួត ៦៣៧ - ទ្រី សាយអាន - ស សាម៉ន ៦២១ អ៊ុក ឆេង ៦២៣ ជាក្រុមក្មេងខិល ហើយធាត់ធំជាមួយគ្នារហូតដល់ពេលចេញពីសាលា - ប៉ុន្តែ ទូត ចាន់ថន ៦១៨ ជាក្មេងឆ្លាត រមទម្យមិនដូចក្រុម ក្មេងមុននោះទេ ។ ម្នាក់ៗសុទ្ធតែធ្លាប់ទទួលទោសតិច ឬច្រើនតែរឿងៗខ្លួន... ចាន់ធួន ធ្លាប់ត្រូវលោកកុម្មង់ដង់ ទឹម ថូ ដាក់គុក ៣ថ្ងៃ ដោយសារមិនមានវត្តមាននៅពេលទៅទទួល"សម្តេចឪ"ដែលបានយាងមកកំពង់ចាម, ចាន់ធួន ភ័យខ្លាំងណាស់ ពីព្រោះលោកកុម៉ង់ដង់ចោទប្រកាន់ថា"បើមានភេរវករណាធ្វើឱ្យមានផ្ទុះគ្រាប់បែកណាមួយក្បែរសម្តេចនោះ ឯងនឹងត្រូវគេចោទប្រកាន់បានភ្លាម..." តែអ្វីៗដំណើរការតាមដំណើរស្លូកងទ័ពយ៉ាងរលូន រហូតដល់ថ្ងៃដែលពួកគេគ្រប់អាយុ១៨ឆ្នាំ ត្រូវចេញពីសាលា ទូត ចាន់ធួន នឹងសិស្សកុមារយោធា៣0រូប ដែលត្រូវចេញទៅបន្តវិជ្ជាជានាយទាហ៊ានរង នៅខេត្តពោធិសត្វ ត្រូវទៅពិនិត្យសុខភាពពេលចេញពីសាលាទៅកាន់មជ្ឈមណ្ឌលថ្មី -នៅពេលនោះ អាឆេងភ័យណាស់ ពីព្រោះវាមានពងតែ១ ចំណែកអ្នកឯទៀតមានពងដល់ទៅ២ ខុសគ្នាដូច្នេះ អាឆេងនឹងថាគេនឹងឱ្យវា"ធ្លាក់វិញ្ញាសារ"នោះជាមិនខានមិនអាចទៅជានាយទាហ៊ានបានទេ...ដូច្នេះវាក៏អង្វរអាចាន់ធួនឱ្យជួយវាផង... អាចាន់ ធួន នៅតែ ជាក្មេងខូច តែមិនអាចមិនជួយពួកម៉ាកបានទេ ក៏ប្រថុយនៅពេលគេហៅឈ្មោះ"អ៊ុក ឆេង" វាក៏ទៅបង្ហាញខ្លួនម្តងទៀត ក្នុងឈ្មោះ"អ៊ុក ឆេង"ទៅដោយសង្ឃឹមថា គ្រូពេទ្យនោះនឹងមិនចាំមុខខ្លួននោះទេ... មែនគ្រូពេទ្យនោះមិនបានឆែកឈ្មោះសិស្សកំហូចនោះទេ អាឆេងក៏បានជាប់ឈ្មោះទៅពោធិសត្វពេលនោះទៅ ហើយសិស្ស អ៊ុកឆេង នៅតែអាចក្លាយជាទាហ៊ានគ្រប់លក្ខណៈដូចគេឯងតែដដែល ។

សិស្សកុមារយោធិន្ទ មិនមែនត្រឹមតែទៅរៀនសាលាដូចកុមារធម្មតាតែប៉ុណ្ណោះនោះទេ នៅពេលឈប់សម្រាប់ពេលខ្លី មិនអាចចេញទៅណាដោយគ្មានការអនុញ្ញាតិជាលាយលក្ខណ៏អក្សរនោះបានទេ គេត្រូវទទួលការហាត់ហ្វឹកហ្វឺនវិជ្ជាយោធាថែមទៀត មានការហាត់ដើរជាក្បួន មានការហាត់បាញ់កាំភ្លើង មានការរៀនវិជ្ជាកងទ័ពក្នុងបេសកកម្មជាប្រចាំផង ។

១ខែម្តង មានការត្រួតពិនិត្យកន្លែងដេករបស់សិស្សដោយមេបញ្ជាការតែម្តង ។ សិស្សម្នាក់ៗត្រូវសំអាតគ្រែដេកខាត់ឱ្យរលោងបោកកម្រាលពូក ស្រោមខ្នើយ រលាស់កន្ទេលកុំឱ្យមានធូលី ឬសង្កើច សំអាតក្រោមគ្រែហិបដាក់ខោអាវទាហ៊ានរៀបនឹងអ៊ុតឱ្យស្អាត ខាត់ស្បែកជើងឱ្យភ្លឺរលោង ខាត់ក្បាលខ្សែក្រវ៉ាត់ឱ្យភ្លឺដូមាស...អ្វីៗត្រូវតែស្អាតឥតខ្ចោះ ។ សិស្សម្នាក់ៗ ក្នុងឯកសណ្ឋានក្រុងមិនបាក់"ភ្លី"ស្បែកជើងភ្លឺច្រាលបេរ៉េក្រហមត្រូវរង់ចាំលោកកុម៉ង់ដង់នៅជើងគ្រែរបស់ខ្លួន ហើយត្រូវស្រែកបង្ហាញខ្លួន នៅពេលកុម៉ង់ដង់មកដល់។ (នៅមានត)



# កម្មវិធីជំនួយផ្នែកថែទាំសុខភាពតាមផ្ទះរដ្ឋ

## AccuCare

### Home Care Agency

Group Adults Foster Care Program

កម្មវិធី Group Adult Foster Care (GAFC) គឺជាដំណោះស្រាយល្អបំផុតសំរាប់ចាស់ៗ ខ្មែរយើងដែលមានបញ្ហារ៉ាំរ៉ៃផ្នែកសុខភាព ឬជរា ហើយមិនចង់ចាកចេញពីលំនៅដ្ឋានខ្លួនឯង ឬមិនចង់បែកពីក្រុមគ្រួសារដែលបានរស់នៅជាមួយគ្នាជាយូរមកហើយ។ យើងអាចជួយអោយជីវិតលោកអ្នកកាន់តែប្រសើរឡើង តាមរយៈការផ្តល់នូវសេវាថែទាំសុខភាពមួយទល់មួយដល់ផ្ទះលោកអ្នកតែម្តង ។





**ដើម្បីអាចចូលរួមក្នុងកម្មវិធីនេះបានលោកអ្នកត្រូវមានលក្ខណៈដូចខាងក្រោម :**

- រស់នៅផ្ទះរដ្ឋ
- អាយុ ២២ ឆ្នាំឡើងទៅ
- មានម៉ែហិលស្តង់ដា

**ផលប្រយោជន៍ទទួលបាន :**

- ការថែទាំផ្ទាល់ខ្លួនមួយ ទល់មួយក្នុងផ្ទះរបស់អ្នករាល់ថ្ងៃមួយថ្ងៃមួយម៉ោងលើការរស់នៅប្រចាំថ្ងៃ
- ជំនួយលើការគ្រប់គ្រងថ្នាំសង្កូវអ្នក
- ផែនការថែទាំសុខភាពផ្ទាល់ខ្លួនមួយ ដែលធ្វើឡើងដោយគ្រូពេទ្យ និងខេសមានីជើ
- វាយតំលៃលើសេចក្តីត្រូវការជាប្រចាំជាបន្តបន្ទាប់
- សមាជិកអាចទាក់ទងមក២៤ម៉ោង

***To be eligibled for GAFC you must:***

- *live in subsidized or public housing*
- *age 22 years and older*
- *eligible for Masshealth Standard*

***Benefits you will get:***

- *personal care service in your home,*
- *Medication Managemant*
- *an individual care plan developed by a registered nurse and case manager*
- *ongoing monitoring of needs*
- *24-hour access to services*

**ត្រូវការជ្រើសរើសបុគ្គលិកធ្វើការ PCA/ HHA needed**
**for Lowell, Lynn, Revere, and Boston**

ជាសេវាមានគុណភាពខ្ពស់ និងទុកចិត្តបាន
បុគ្គលិកមានសណ្តានចិត្តល្អ និងធ្វើការតាមវិជ្ជាជីវៈ
អ្នកគ្រប់គ្រង និងបុគ្គលិកនិយាយភាសាខ្មែរ

**ដើម្បីចុះឈ្មោះសូមទាក់ទងមក**
To register, please contact:
Tel: (978)735-4955, Fax: (978) 735-4956
Office: 144 Merrimack St., Suite 404. Lowell, MA 01852

# ភ្លើងឆេះព្រៃនៅកាលីហ្វ័រញ៉ាបានសម្លាប់មនុស្ស ៨៧ នាក់ និងជិត ៤០០ នាក់បាត់ខ្លួន

មានមនុស្សជាច្រើនបានស្លាប់ និងរាប់រយនាក់នៅតែបន្តបាត់ខ្លួនបន្ទាប់ពីមានភ្លើងឆេះព្រៃដ៏ខ្លាំងបំផុតដែលមានឈ្មោះថា Camp Fire បានលិចចេញរូបរាងឡើងនៅភាគខាងជើង និងខាងត្បូងរដ្ឋកាលីហ្វ័រនីញ៉ាកាលពីដើមខែនេះ ។ យោងតាមការដកស្រង់សំដីរបស់មន្ត្រីក្រសួងព្រៃឈើ និងការទុបស្កាត់អគ្គីភ័យរដ្ឋកាលីហ្វ័រញ៉ាពីសំណាក់កាសែត អាបេសេ កាលពីថ្ងៃទី ២៣ ខែវិច្ឆិការនេះ បានឱ្យដឹងថា ភ្លើងឆេះព្រៃពីរដែលបានឆាបឆេះកាលពីដើមខែនេះបានឆក់យកជីវិតមនុស្សយ៉ាងហោចណាស់ ៨៧នាក់ ព្រមទាំងបានបន្សល់ទុកនូវកាកសំណល់នៃការឆេះដែលមានទំហំសរុបចំនួនជិត ៤០០ ម៉ាយការ៉េ ។ ប្រភពដដែរបានបញ្ជាក់ថា សាកសពយ៉ាងហោចណាស់៥៤នាក់ត្រូវបានកំណត់អត្តសញ្ញាណមកទល់ពេលនេះ ។













ភាគច្រើននៃចំនួនអ្នកស្លាប់ទាំងអស់មានចំនួន៨៤នាក់ដោយសារតែភ្លើងឆេះព្រៃ Camp Fire នៅប៊េតខោនធ្រី (Butte Country) នៃរដ្ឋកាលីហ្វ័រនីញ៉ាភាគខាងជើង ដែលធ្វើឱ្យវាក្លាយជាភ្លើងឆេះព្រៃដែលបំផ្លិចបំផ្លាញ និងសម្លាប់មនុស្សច្រើនបំផុតនៅក្នុងប្រវត្តិសាស្ត្រនៃគ្រោះមហន្តរាយភ្លើងឆេះព្រៃក្នុងរដ្ឋ ។ តួលេខចំនួនមនុស្សដែលបាត់ខ្លួន នៅប៊េត

តទៅទំព័រទី១៥


MARCOTTE LAW FIRM

ក្រុមហ៊ុនមេធាវី Marcotte

45 MERRIMACK STREET
LOWELL, MASSACHUSETTS
(978) 458-1229

- សេចក្តីអន្តរាយដល់បុគ្គល
- សំណងបុគ្គល
- ពិការភាពដោយសន្តិសុខសង្គម
- បទព្រហ្មទណ្ឌផ្លូវភេទ និងថ្នាំញៀន
- ច្បាប់គ្រួសារ និងផែនការអចលនទ្រព្យ
- បណ្តឹងវិវាទទូទៅ
- បើកបរនៅពេលស្រវឹង និងប្រព្រឹត្តបទល្មើសពេលធ្វើចរាចរណ៍
- ច្បាប់ធានារ៉ាប់រង
- ការរំលោភបទព្រហ្មទណ្ឌ
- គ្រោះថ្នាក់ចរាចរណ៍
- គ្រោះថ្នាក់នៅការដ្ឋាន
- បំណុលអចលទ្រព្យ

មានបុគ្គលិកនិយាយភាសាខ្មែរលោកអ្នកអាចហៅទូរស័ព្ទមកក្រុមហ៊ុនយើងខ្ញុំដើម្បីពិគ្រោះ

(978) 458-1229

www.marcottelawfirm.com





CONWAY
INSURANCE AGENCY

រយៈពេល២៥ឆ្នាំ ភ្នាក់ងារធានារ៉ាប់រងខុនវ៉េយបានបម្រើសហគមន៍ដោយធានារ៉ាប់រងគ្រប់មុខប្រកបដោយគុណភាពនៅតំបន់ញូអ៊ីងឡែន ។

យើងខ្ញុំជាភ្នាក់ងារបំពេញសេវាគ្រប់មុខដូចខាងក្រោម :

ការធានារ៉ាប់រងគ្រួសារ

- រថយន្ត
- ផ្ទះ
- ផ្ទះល្វែង
- គ្រឿងអលង្ការ
- វត្ថុសិល្បៈ
- វត្ថុបុរាណ

ការធានារ៉ាប់រងជំនួញ

- អចលនវត្ថុ
- សុវត្ថិភាពជំនួញ (Liability)
- សុវត្ថិភាពជំនាញ (Professional Liability)
- ថៃខឺខម (Worker's Compensation)
- បនដស៍ (Bonds)
- អ្នកមើលថែឡាន និងការលក់ឡាន
- ធានារ៉ាប់រងពិការភាព និងជីវិត
- កម្មវិធីពិសេសផ្សេងៗទៀត

CONWAY
INSURANCE AGENCY

77 E. Merrimack Street. Lowell, MA 01852
Tel: 978-454-5054|Fax 978-453-2480
www.conwayinsurance.com
សូមទាក់ទងមក : ហ្វីលីប មុត, អ្នកគ្រប់គ្រង

## State of Rhode Island

**The Department of Children Youth and Families** is currently seeking candidates for its **20th Rhode Island Training School Pre-Service Academy.**

APPLICATION PERIOD: All resumes must be received by **December 31, 2018**. Interested parties should submit resume to the address listed below:

**Department of Children, Youth and Families**
Attn: Janet Mahoney
101 Friendship Street
Providence, RI 02903
(401) 528-3417

**Open house and informational sessions will be at the following locations, dates and times:**

| | | |
|---|---|---|
| Community College of Rhode Island - CCRI<br>400 East Ave<br>Warwick RI 02886<br>**Nov. 21, 2018 9:30 AM-10:30 AM** | Rhode Island Training School: Thomas C. Slater Youth Development Center<br>57 Power Rd.<br>Cranston, RI 02920<br>**November 26, 2018 1:00 PM-2:00 PM and 5:00 PM-6:00 PM** | Rhode Island Training School: Thomas C. Slater Youth Development Center<br>57 Power Rd.<br>Cranston, RI 02920<br>**Nov. 27, 2018 1:00 PM-2:00 PM and 5:00 PM-6:00 PM** |
| Harvest Kitchen<br>2 Bayley St,<br>Pawtucket, RI 02860<br>**November 28, 2018 10:00 AM-12:00PM** | Tides/Youth Transition Center<br>215 Washington St<br>West Warwick, RI 02893<br>**November 28, 2018 4:00 PM-5:00 PM** | Tides/Youth Transition Center<br>790 Broad Street<br>Providence R.I. 02905<br>**December 1, 2018 4:00 PM-5:00 PM** |

After graduating from Pre-Service Training Academy candidates may be placed on a hiring list and offered employment upon positions becoming available

For more information visit:
http://www.dlt.ri.gov/jobsri/statejobs.htm
or call **Victor Mendoza at 401-222-3900**

**Benefits and Salary (upon appointment):**
State medical, and life insurance benefits package, salary range from $44,093-$50,043, paid vacation and sick leave and college reimbursement programs.

**Minimum Qualifications and Educational Requirements:**
Qualified applicants must possess the minimum qualifications of being 21 years or older and possess a valid Rhode Island driver's license. Qualified applicants must also possess a minimum of an associate's degree acquired from an accredited college and experience working with adolescent youth.

**Application Process:**
Qualified applicants must submit to a BCI/NCIC background clearances, Child Protective Services background clearances, a Drug Screen, a Physical Fitness assessment Battery, Interview Panels and a Psychological Screen. The Physical Fitness Assessment Battery standards are as follows:

**SPECIAL REQUIREMENTS:**
At the time of appointment applicants must be capable of performing (with or without reasonable accommodation) the essential duties as evidenced by a physician's certificate and must continue to be qualified to perform assigned duties through employment. Must have successfully completed and graduated from Department of Children, Youth and Families Juvenile Correction Pre-Service Training Program. In accordance with RIGL 42-28.3-1 no person shall be appointed temporary, probationary, or permanent until they shall have been evaluated and tested by a certified psychologist and receive a satisfactory rating which shall be in writing.


ការិយាល័យច្បាប់
រ៉ូសា និង តាំង



Francisco J. Rosa, Esq.
មេធាវី ហ្វ្រង់ស៊ីស្កូ ជេ.រ៉ូសា



Andrew 'Bunna' Taing, Esq.
មេធាវី អែន ទ្រឺវប៊ុណ្ណា តាំង

Law Office of
Rosa & Taing
ATTORNEY AT LAW

SERVICES
- Auto Accidents/ Personal Injury
- Bankruptcy
- Immigration
- Consumer Protection
- Real Estate Closings/Disputes
- Divorces Child Custody

កំណាងក្ដីដូចខាងក្រោម
- គ្រោះថ្នាក់រថយន្ត/ របួសរូបរាងកាយ
- ក្ស័យធន
- អន្តោប្រវេសន៍
- ការពារអតិថិជន
- ទិញលក់ផ្ទះអចលនវត្ថុ
- លែងលះ និងអាណាព្យាបាលកិច្ច

1550 Middlesex Street Lowell, MA 01851
Phone: **978-458-0934** | at@rosataing.com



LEGEND
MOTOR GROUP, INC.
ហាងជួលជុសរថយន្ត លេជេន

មានសេវាជួលជុលរថយន្តគ្រប់ប្រភេទ
រយន្ត ប៉ះ បុក ខូចខាត និងក្រពិតមែន រឺទេ ?
ទូរស័ព្ទ 978-458-2085

COLLISION REPAIR
BEEN IN AN ACCIDENT?
FROM DENTS TO TOTALED,
WE CAN FIX IT ALL.



យើងរៀបចំសណ្ដោងរថយន្ត នៅពេលត្រូវការ, ធ្វើការជាមួយនឹង
ក្រុមហ៊ុនធានារ៉ាប់រងរបស់លោកអ្នកនិងរៀបចំរាល់ឯកសារទាំងអស់។
ការពេញចិត្តរបស់លោកអ្នក គឺជាអាជីវកម្មរបស់យើង។

115 Rock St. Unt #7 Lowell, MA 01854

**KhmerPost USA, LLC**
សារពត៌មានខ្មែរផុសសហរដ្ឋអាមេរិក

លេខទូរស័ព្ទ Phone: 978 677-7163 | Fax: (978) 677-7092
អ៊ីម៉ែល info@khmerpost.us
អានកាសែតនៅគេហទំព័រ www.khmerpost.us

ផ្សាយពាណិជ្ជកម្ម Advertising
អគ្គនាយក សុបិន្ត ពិន Soben Pin, *Co-Founder/Publisher*
លេខទូរស័ព្ទ 978 - 656 - 8141 (Mobile) 978 677-7163 (Office)
អ៊ីម៉ែលsobenpin@khmerpost.us

អ្នកនិពន្ធ Editorials
និពន្ធនាយក ពិន សំខុន Roger Samkhon Pin, *Co-founder/Editor*
(978) 942 - 1641 | rogerpin@khmerpost.us
ការីនិពន្ធ Staff Writers:
អ្នកនិពន្ធកិត្តិយស Staff Writer/Translator
Sokharath Koy
ច្នៃសោភ័ណភាពកាសែត Design Artist
Heng Chhunleng

The KhmerPost USA is a free biweekly Cambodian newspaper and serves the Greater Merrimack Valley, Boston, and Rhode Island. It prints mostly in Khmer and provides important news and information to the people who often are isolated from the larger community due to a language barrier. This includes not only national and international news but practical local information concerning health, education, politics, businesses and community involvement. It publishes twice a month from Lowell, Massachusetts.

Mail subscription is available within the U.S. & Canada at $60.00 year.

Follow us: Facebook | Twitter KhmerpostUSA

**REACH THOUSANDS OF PEOPLE IN THE CAMBODIAN COMMUNITY WITH**
**COST EFFECTIVE NEWSPAPER ADVERTISING**




**PUBLISHING**
*Two Issues Every Month*

**READERSHIP**
*50,000 Monthly*
*600,000 Annually*

***Khmer Post USA Distribution Locations:***

- Households
- Markets
- Retail Businesses
- Restaurants
- Office Buildings
- Government Offices
- Chamber of Commerce
- Buddhist Temples
- Laundromats
- And Much More

KhmerPost USA is a free Cambodian-English biweekly newspaper serving Lowell, Chelmsford, Tyngsboro, Lynn and Revere, MA as well as Cranston and Providence, RI.

It was founded in 2007 by Soben Pin and partner Roger Pin. In 2010, they relocated the newspaper to Lowell to meet the demand for readership.

With an annual readership of 600,000, it is the only premier voice for the Cambodian-American community across the New England region.

**www.khmerpost.us**

តមកពីទំព័រទី ១៣

# ភ្លើងឆេះព្រៃនៅកាលីហ្វ័រញ៉ាបានសម្លាប់..

ខោនទ្រីបានធ្លាក់មកត្រឹមតែ៤៧៥នាក់ បន្ទាប់ពី ប៉ុន្តែតួលេខនេះ ត្រូវបានគេរំពឹងទុកថានឹងមានការប្រែប្រួល។ មានក្រុមភ្នាក់ងារពន្លត់អគ្គីភ័យចំនួន៨២០នាក់កំពុងបន្តស្វែងរកអ្នកបាត់ខ្លួន និង ជួយសង្គ្រោះនៅថ្ងៃព្រហស្បតិ៍ ជាមួយគ្នានោះដែរក៏មានសមត្ថកិច្ចជាង១០០នាក់ដែលឈរជើងការពារតំបន់ដែលត្រូវជម្លៀសចេញដោយសារតែជំរុំអគ្គីភ័យនេះ។

រហូតមកដល់ពេលនេះក្រុមការងារចំរុះ បានចាប់យករូបភាពពីលើអាកាសនៃតំបន់ក្រុងផារាដាយ (Paradise) ដែលទទួលរងការខូចខាតច្រើនជាងគេ និងបានថតវីដេអូជូននូវផ្លូវសំខាន់ៗទាំងអស់នៅក្នុងតំបន់ផងដែរដើម្បីទទួលបានព័ត៌មានសំខាន់ៗនៃពលរដ្ឋនៅក្នុងសហគមន៍ដែលទទួលគ្រោះដោយសារភ្លើងឆេះព្រៃ Camp Fire ។

គួរបញ្ជាក់ថាក្រុមភ្នាក់ងារពន្លត់អគ្គីភ័យបានធ្វើឱ្យមានការរីកចម្រើនគួរឱ្យកត់សម្គាល់ក្នុងការពន្លត់ភ្លើងឆេះព្រៃទាំងពីរនៅក្នុងរយៈពេលប៉ុន្មានថ្ងៃថ្មីៗនេះ ហើយភ្លៀងជាច្រើនបានធ្លាក់ និងបានគ្របដណ្តប់លើតំបន់ដែលឆេះ។ ទោះជាយ៉ាងណាក៏ដោយភ្លៀងធ្លាក់ខ្លាំង បាននាំមកនូវគ្រោះថ្នាក់ថ្មីដល់តំបន់ដែលទទួលរងការឆាបឆេះ ដូចជាទឹកជំនន់មួយរំពេច និងការរអិលបាក់ដី ជាពិសេសនោះ គឺនៅភាគខាងជើងកាលីហ្វ័រនីញ៉ា។





# កម្មវិធី វើល អេដ ដេយ នៅឡូវែល

កម្មវិធីវើល អេដ ដេយ (World Aidds Day) នឹងរៀបចំឡើងនៅឡូវែលនៅថ្ងៃសុក្រ ទី ៣០ ខែវិច្ឆិការខាងមុខនេះនៅទីតាំងមណ្ឌលឡូវែលខាំញ៉ូនីធី ហែលស៊ិនធ័រ ដែលមានអាស័យដ្ឋានផ្លូវ 161 Jackson St។ ក្រុងឡូវែលចាប់ពីម៉ោង ៥ ល្ងាច ដល់ម៉ោង៨យប់។

កម្មវិធីដោយមិនគិតថ្លៃនេះ មានដូចជាម្ហូបអាហារ, ការឡើងបច្ចេញមត្តិ និងចំណាប់អារម្មណ៍, ការផ្តល់រង្វាន់, ព័ត៌មាន, និងតន្ត្រី។ មិនចាំចាប់ចំណាយក្នុងការចូលរួម និងការកក់ជាមុននោះទេ។ សូមស្វាគមន៍គ្រប់អ្នកចូលរួមទាំងអស់។

សម្រាប់ព័ត៌មានបន្ថែម, សូមទំនាក់ទំនងមកកាន់ សេឌី ហ្វាជូហា (Sade Farquhar), អ្នកសម្របសម្រួល តាមរយៈអ៊ីម៉ែល SadeFa@lchealth.org ។

# World AIDS Day in Lowell

World AIDS Day will be recognized locally on Friday, November 30, at Lowell Community Health Center, 161 Jackson St. in Lowell, from 5:00 to 8:00 PM.

This free annual event includes a light supper, speakers, awards, information and music. There is no cost to attend and no reservations are necessary. All are welcome.

For more information, contact Committee Coordinator Sade Farquhar, SadeFa@lchealth.org.

# SEE VICHET CHUM AS AN ENGLISH LORD IN CHRISTMAS AT PEMBERLEY!

NOW – DEC 23

## MISS BENNET: CHRISTMAS AT PEMBERLEY

BY Lauren Gunderson *(Silent Sky, I and You)* and Margot Melcon

DIRECTED BY Sean Daniels

Vichet Chum, writer and performer of last sesson's *KYNUM*, stars as a wealthy scholar who longs for the perfect wife in this sparkling comedy, a sequel to Jane Austen's *Pride and Prejudice.*

"**DELICIOUS**. . . highly entertaining, the kind of thing multiple generations can enjoy together." -CHICAGO TRIBUNE

**$10 OFF**
*LIMITED SEATS!*

**BOOK NOW**
AT 978-654-4678
OR MRT.ORG

USE PROMO CODE
**CELEBRATE**

**STUDENTS TICKETS $15**



Artwork by Chris Holden



VICHET CHUM

***DISCOUNTS:** Use code CELEBRATE for $10 off tickets. $10 discount not valid on SuperSaver seats. Valid only for performances through Dec. 16, limited availability at this rate. Show recommended for ages 10 and up. Discount cannot be combined with other offers. No refunds, no exchanges, all sales final. Adult students, ID required.

circlehealth — Complete connected care — SEASON SPONSOR

Lupoli COMPANIES — PRODUCTION SPONSOR

merrimack valley magazine / 90.9 wbur — MEDIA SPONSOR

MERRIMACK REPERTORY THEATRE

LOWELL, MA | MRT.ORG